**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច . ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩០៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីរាជការ ចំនួន ០៤រូប នៃក្រសួងពាណិជ្ជកម្ម ដូចមានរាយនាមខាងក្រោម ៖

១- លោកស្រី **គង់ សិទ្ធិកា** ជាអគ្គនាយករងពាណិជ្ជកម្មក្នុងប្រទេស ជំនួស លោក អ៊ុយ សុខារាត្ត ដែលបានចូលនិវត្តន៍

២- លោក **ជាន អូន** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ជំនួស ឯកឧត្តម ហេង សុខុម ដែលបានចូលនិវត្តន៍

៣- លោក **ម៉ក់ ឧសភា** ជាប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ជំនួស ឯកឧត្តម មាន សុភា ដែលបានចូលនិវត្តន៍

៤- លោក **អ៊ុច គឹមយ៉ុន** ជាជំនួយការក្រសួងពាណិជ្ជកម្ម ប្រចាំនៅរដ្ឋបាល តំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន-តាយសេងបាវិត មានឋានៈស្មើ ប្រធាននាយកដ្ឋាន

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ កក្កដា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្ត ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

## សម្រេច

**មាត្រា ១** : ប្រគល់ភារកិច្ចជូនលោក **តូច ណារត្ន** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ក្រសួងព័ត៌មាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ២*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥០៤ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ប្រគេន និងជូន**មេដាយស្ថាបនាជាតិ** ចំពោះព្រះតេជគុណ និងសប្បុរសជន ដែលមានស្នាដៃក្នុងការកសាងសមិទ្ធផលនានា ក្នុងស្រុកកំរៀង និងស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ដូចមានរាយព្រះនាម និងនាមខាងក្រោម :

**ក_មេដាយស្ថាបនាជាតិ ថ្នាក់ មាស ចំនួន ០១គ្រឿង** ប្រគេន :

ព្រះតេជគុណ**សុខ សុខន** ព្រះអនុគណស្រុកកំរៀង និងជាចៅអធិការវត្តគិរីរតនៈ

**ខ_មេដាយស្ថាបនាជាតិ ថ្នាក់ ប្រាក់ ចំនួន ០៨គ្រឿង** ជូនចំពោះ :

១-អ្នកស្រី **ហេង សុជាតិ** សប្បុរសជនស្រុកកំរៀង
២-អ្នកស្រី **នេត វឿន** សប្បុរសជនស្រុកកំរៀង
៣-លោក **អ៊ី អុន** សប្បុរសជនស្រុកកំរៀង
៤-អ្នកស្រី **សឹង ញឿន** សប្បុរសជនស្រុកកំរៀង
៥-អ្នកស្រី **តាន ស៊ីណា** សប្បុរសជនស្រុកកំរៀង
៦-អ្នកស្រី **ចឹម សុខនេង** សប្បុរសជនស្រុកកំរៀង
៧-អ្នកស្រី **សឿន សារី** សប្បុរសជនស្រុកកំរៀង
៨-អ្នកស្រី **ម៉ាត សាម៉ន** សប្បុរសជនស្រុកកំរៀង

**គ-មេដាយស្ថាបនាជាតិ ថ្នាក់ សិរីវឌ្ឍ ចំនួន ០៧គ្រឿង** ប្រគេន និងជូនចំពោះ :

| | | |
|---|---|---|
| ១-ព្រះតេជគុណ | **ឈុន មន្នី** | ព្រះគ្រូសូត្រវត្តគិរីរតនៈ |
| ២-ព្រះតេជគុណ | **ញៀម ជន** | ព្រះគ្រូសូត្រស្តាំវត្តគិរីរតនៈ |
| ៣-អ្នកស្រី | **មៀច សុខុម** | សប្បុរសជនស្រុកកំរៀង |
| ៤-អ្នកស្រី | **លៀម ឡុម** | សប្បុរសជនស្រុកកំរៀង |
| ៥-លោក | **អិន ភន** | គណៈកម្មការវត្តគិរីរតនៈ |
| ៦-លោក | **ឆេព កុសល** | គណៈកម្មការវត្តគិរីរតនៈ |
| ៧-លោក | **ស៊ុត សុវណ្ណ** | គណៈកម្មការវត្តគិរីរតនៈ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ០៧ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥០៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** បំពាក់មេដាយស្ថាបនាជាតិ **មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** និងមេដាយស្ថាបនាជាតិ **ថ្នាក់ មាស** ជូនសប្បុរសជន ដែលបានរួមចំណែកកសាងជាតិមាតុភូមិកម្ពុជាលើវិស័យទឹកស្អាតឱ្យមានការរីកចម្រើននៅក្រុងបាត់ដំបង ខេត្តបាត់ដំបង ជាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន តាមរយៈអង្គការ JICA ដូចមានរាយនាមខាងក្រោម :

**ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ចំនួន ០២គ្រឿង** ជូនចំពោះ :

១-លោក **ហ្វូជីវ៉ារ៉ា ហ៊ីរ៉ូគិ** (FUJIWARA HIROKI)

២-លោក **គីយ៉ាម៉ា សាតូស៊ី** (KIYAMA SATOSHI)

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ សេនា ចំនួន ០៨គ្រឿង** ជូនចំពោះ :

១-លោក **អ៊ីស៊ី ហ៊ីដេអូ** (ISHII HIDEO)

២-លោក **អាបេ ណូប៊ុគិ** (ABE NOBUKI)

៣-លោក **សាគីយ៉ាម៉ា ណូប៊ុកាស៊ុ** (SAKIYAMA NOBUKATSU)

៤-លោក ណាកាតា ណូរីយុគិ (NAGATA NORIYUKI)

៥-លោក មីអ៊ូរ៉ា អាគីរ៉ា (MIURA AKIRA)

៦-លោក កាស៊ូហ៊ីតូ សាតូ (KAZUHITO SATO)

៧-លោក ណាអូគី អ៊ីហារ៉ា (NAOKI IHARA)

៨-លោក កេនស៊ូកេ យ៉ាស៊ូ (KENSUKE YASUE)

គ. គ្រឿងឥស្សរិយយសស្ថាបនាជាតិ ថ្នាក់ មាស ចំនួន ០២គ្រឿង ជូនចំពោះ :

១-លោក ហោ ដេន (HOR DEN)

២-លោក ឈរ រដ្ឋា (CHHOR RATHA)

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ០៧ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥០៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកាជួយកសាងសមិទ្ធផលលើវិស័យព្រះពុទ្ធសាសនា នៅវត្តទួលពង្រនិងវត្តស្ទឹងបត់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-ព្រះតេជគុណ | **ចិន្ត សំអុន** | បច្ច័យចំនួន ១០.០០០ ដុល្លារ |
| ២-ព្រះតេជគុណ | **តឿ ម៉ុនធឿន** | បច្ច័យចំនួន ១០.០០០ ដុល្លារ |
| ៣-អ្នកស្រី | **ហេង ថារិន** | ថវិកា ចំនួន ១១.៥០០ ដុល្លារ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ ចំនួន០២អង្គ ដែលបានបរិច្ចាគបច្ច័យជួយកសាងសមិទ្ធផលលើវិស័យព្រះពុទ្ធសាសនា នៅវត្តទួលពង្រ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :**

-ព្រះតេជគុណ **ញៀម សឿន** បច្ច័យចំនួន ៣៥.០០០ ដុល្លារ

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

-ព្រះតេជគុណ **ណយ ណេត** បច្ច័យចំនួន ២០.០០០ ដុល្លារ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន១២រូប ដែលបានបរិច្ចាគបច្ច័យនិងថវិកាចូលរួមជួយកសាងព្រះវិហារ និងសមិទ្ធផលនានា នៅវត្តសាគរអូរជ្រៅ ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ព្រះតេជគុណ | **ខ៊ែត ទ៊ាន** | បច្ច័យ ចំនួន ៤២.៥៩៨ ដុល្លារ |
| ២-លោក | **យន់ ឆេង** | ថវិកា ចំនួន ១៩.៧៧៥ ដុល្លារ |
| ៣-លោក | **ឥន្ទ ជីប** | ថវិកា ចំនួន ១៩.២៩៨ ដុល្លារ |
| ៤-លោក | **ឆែម ជាតិម្ទេស** | ថវិកា ចំនួន ១៨.៧៩០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-លោក | **សោម សារិន** | ថវិកា ចំនួន ៧.៣២៥ ដុល្លារ |
| ២-លោក | **ណុប ស៊ាន** | ថវិកា ចំនួន ៧.២៥៩ ដុល្លារ |
| ៣-លោក | **ឈឹម សេង** | ថវិកា ចំនួន ៧.១២៥ ដុល្លារ |
| ៤-លោក | **ហុក តៅ** | ថវិកា ចំនួន ៧.១២០ ដុល្លារ |
| ៥-លោក | **ឯម ឆេង** | ថវិកា ចំនួន ៧.០០០ ដុល្លារ |
| ៦-លោក | **សាយ រ៉ា** | ថវិកា ចំនួន ៧.០០០ ដុល្លារ |
| ៧-អ្នកស្រី | **អ៊ឹង សំបូរ** | ថវិកា ចំនួន ៧.០០០ ដុល្លារ |
| ៨-អ្នកស្រី | **លី ហុកអេង** | ថវិកា ចំនួន ៧.០០០ ដុល្លារ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧០.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះសង្ឃ ចំនួន០៣អង្គ ដែលបានបរិច្ចាគបច្ច័យចូលរួមជួយកសាងព្រះវិហារ និងសមិទ្ធផលនានា នៅវត្តសាគរអូរជ្រៅ ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដូចមានរាយព្រះនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-ព្រះតេជគុណ | **ឈឹម យុត** | ព្រះអនុគណស្រុកព្រៃនប់ |
| ២-ព្រះតេជគុណ | **ប៉ុណ្ណ សុវណ្ណា** | ព្រះគ្រូចៅអធិការវត្តព្រៃនប់ |
| ៣-ព្រះតេជគុណ | **ឈន ចន្ទ** | ព្រះគ្រូចៅអធិការវត្តរតនៈសាគរម៉ាអូរ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ**៥១១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៨រូប ដែលមានស្នាដៃល្អក្នុងការសាងសង់សាលារៀនឥដ្ឋាមមួយខ្នង ០២ជាន់ មាន០៦បន្ទប់ នៅភូមិប្រាំដំឡឹង ឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ :**

១-ឯកឧត្តម **លី ស៊ុគ្រី**
២-លោក **ជាម អេងហួត**
៣-លោក **សា លី**
៤-លោក **ស៊ីត គួច**

**ខ-មេដាយប្រាក់ការងារ :**

១-លោក **សុខលី អាលីខុស្មាន**
២-លោក **ទូលស៊ស ឡី**
៣-លោក **ទ្រេះ ឡា**
៤-អ្នកគ្រូ **ទ្រេះ អែសះ**

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០១៣
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **លី ម៉ុសា** ដែលបានជួយឧបត្ថម្ភដល់ការសាងសង់សាលារៀនឥដ្ឋមួយខ្នង ០២ជាន់ មាន០៦បន្ទប់ ស្ថិតនៅភូមិប្រាំដំឡឹង ឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៧ ឆ្នាំ ២០១៣
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥១៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា ១.-**

បំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២គ្រឿង ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមជួយកសាង កុដិ ០១ខ្នង និងសមិទ្ធផលផ្សេងៗ ស្ថិតនៅក្នុងឃុំស្វាយជ្រំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

១-លោក **ផូ ទាសនា** សប្បុរសជន

២-លោក **លន់ សុវណ្ណៈ** សប្បុរសជន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាល ខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥១៨ . អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា ១.-**

បំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** ចំនួន ០១គ្រឿង ជូនលោក **ហ៊ុន ភយ** មេឃុំស្វាយជ្រំ ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមជួយកសាង កុដិ ០១ខ្នង និងសមិទ្ធផលផ្សេងៗ ស្ថិតនៅក្នុងឃុំស្វាយជ្រំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល សម្រេចបានលទ្ធផលល្អប្រសើរ ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាល ខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥១៥ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរវជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ០៥រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមជួយកសាង សមិទ្ធផលនានា នៅវត្តជ័យមង្គល ស្ថិតនៅក្នុងឃុំស្តី ស្រុកចំការលើ ខេត្តកំពង់ចាម សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយព្រះនាម និងនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១- | ព្រះតេជគុណ | **ខិ ឡេង** | ព្រះចៅអធិការវត្តជ័យមង្គល |
| ២- | លោក | **ម៉ែន ហ៊ុន** | មេឃុំស្តី ស្រុកចំការលើ |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | | |
|---|---|---|---|
| ១- | លោក | **អ៊ូ អ៊េត** | មេភូមិ |
| ២- | ឧបាសិកា | **ជាម ស្រ៊ាន** | សប្បុរសជន |
| ៣- | អ្នកគ្រូ | **គង់ ណារី** | សប្បុរសជន |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៤ .សណន

# សេចក្តីណែនាំ
## ស្តីពី
## ការផ្អាកមិនឲ្យលក់ដូរ និងពិសាគ្រឿងស្រវឹងមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ នៃរដ្ឋសភា ពីថ្ងៃទី២៧ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣

កន្លងទៅ រាជរដ្ឋាភិបាលបានសង្កេតឃើញថា ការពិសាគ្រឿងស្រវឹងគ្រប់ប្រភេទ ភាគច្រើនអាចបង្កឲ្យមានអំពើហិង្សា គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់សង្គម ការប្រព្រឹត្តបទល្មើសនានា ឬករណីខ្លះអាចបណ្តាលឲ្យបាត់សណ្តាប់ធ្នាប់សាធារណៈថែមទៀតផង។ អនុលោមតាមច្បាប់បទបញ្ញា និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងដើម្បីឲ្យដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ នៃរដ្ឋសភា ដែលព្រះរាជាណាចក្រកម្ពុជាខ្លួនឯងបានកំណត់រៀបចំធ្វើនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៣ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ គ្មានអំពើហិង្សា គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ និងបាតុភាពនានា ដែលអាចកើតមានឡើងដោយសារតែការពិសាគ្រឿងស្រវឹងនោះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម:

១-ប្រជាពលរដ្ឋខ្មែរ និងជនបរទេសទាំងអស់ ដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរួមសហការជាមួយរាជរដ្ឋាភិបាល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ពាណិជ្ជករ និងអាជីវករ ដោយត្រូវផ្អាកការលក់ដូរ និងពិសាគ្រឿងស្រវឹងមួយថ្ងៃមុនថ្ងៃបោះឆ្នោតនិងថ្ងៃបោះឆ្នោត ចាប់ពីថ្ងៃទី២៧ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ដើម្បីរួមចំណែកទប់ស្កាត់អំពើហិង្សា ការគំរាមកំហែង ការបំភិតបំភ័យ គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់សង្គម និងបាតុភាពនានា ដែលអាចបណ្តាលមកពីការពិសាគ្រឿងស្រវឹងគ្រប់ប្រភេទ ។ល។

២-ក្រសួង ស្ថាប័ន កងរាជអាវុធហត្ថ កងនគរបាលជាតិ រួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើការបំពាក់បំប៉នដល់មន្ត្រីរាជការក្រោមឱវាទ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងផ្សព្វផ្សាយ អប់រំណែនាំប្រជាពលរដ្ឋខ្មែរ និងជនបរទេសទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួន អនុវត្តការផ្អាកការលក់ដូរ និងពិសាគ្រឿងស្រវឹង ក្នុងគោលបំណងធ្វើឲ្យកិច្ចដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥នៃរដ្ឋសភា ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៣ ខាងមុខនេះ ប្រព្រឹត្តទៅក្នុងបរិយាកាសនយោបាយល្អ សេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សា ។

៣-រដ្ឋមន្ត្រីក្រសួងព័ត៌មាន ត្រូវសហការជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការផ្សព្វផ្សាយសេចក្តីណែនាំនេះ តាមគ្រប់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន ជូនដល់ប្រជាពលរដ្ឋខ្មែរ ជនបរទេស ពាណិជ្ជករ អាជីវករ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ឲ្យបានយល់ជ្រួតជ្រាប និងអនុវត្តឲ្យមានប្រសិទ្ធភាព ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត ត្រូវផ្សព្វផ្សាយអនុវត្តឲ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**
**គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍**
លេខៈ ០៥ សណន

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣

# សេចក្តីណែនាំ

គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍បានពិនិត្យឃើញថា ក្នុងដំណាក់ការយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៧ ខែមិថុនា រហូតដល់ថ្ងៃ ១៧ ខែកក្កដា ឆ្នាំ២០១៣នេះ គ្រប់គណបក្សនយោបាយមានឈ្មោះបោះឆ្នោតទាំងអស់បានដំណើរការតាមកម្មវិធីការងាររបស់ខ្លួនក្នុងបរិយាកាសមួយល្អប្រសើរ ទោះបីមានបណ្តឹងខ្លះៗពាក់ព័ន្ធនឹងការអនុវត្តមិនបានត្រឹមត្រូវតាមបទបញ្ជា នីតិវិធី ក្រមសីលធម៌របស់ គ.ជ.ប ។ ប៉ុន្តែពេលថ្មីៗកន្លងមកនេះ មានជនទុច្ចរិតមួយចំនួនបានក្លែងបន្លំឯកសារស្ទង់មតិរបស់វិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ(IRI) ក្នុងបំណងបំពុលបរិយាកាសនយោបាយ ដែលនេះជាទង្វើមួយសំដៅបំផ្លាញនូវដំណើរការបោះឆ្នោតដែលសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព ។

អាស្រ័យហេតុនេះ គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ណែនាំដល់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ថ្នាក់ក្រោមជាតិទាំងអស់ ចេញបទបញ្ជាជាបន្ទាន់ដល់រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ ភ្នាក់ងារសន្តិសុខបោះឆ្នោត នគរបាល កងរាជអាវុធហត្ថ ដូចខាងក្រោមនេះៈ

១-ស៊ើបអង្កេត ស្រាវជ្រាវស្វែងរកចាប់ឃាត់ខ្លួនជន ឬក្រុមជនទុច្ចរិតដែលជាអ្នករៀបចំធ្វើឯកសារក្លែងបន្លំនេះ និងជន ឬក្រុមជនដែលប្រើប្រាស់ឯកសារក្លែងបន្លំនេះ ដើម្បីធ្វើការឃោសនាក្នុងចំណោមមហាជន ប្រជាពលរដ្ឋ បញ្ជូនខ្លួនជនប្រព្រឹត្តបទល្មើស និងឯកសារភស្តុតាងទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់ជាបន្ទាន់ ។

២-សហការជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ធ្វើការផ្សព្វផ្សាយអប់រំទូលំទូលាយជូនដល់ប្រជាពលរដ្ឋកុំឲ្យមានការភ័ន្តច្រឡំ ច្របូកច្របល់ និងបញ្ជាក់ជូនប្រជាពលរដ្ឋឲ្យយល់ច្បាស់ នេះគ្រាន់តែជាចេតនាដើម្បីធ្វើឲ្យប៉ះពាល់ដល់ស្ថេរភាពសង្គម ភាពអសន្តិសុខ និងចលាចលសង្គម ព្រមទាំងអំពាវនាវដើម្បីប្រជាពលរដ្ឋជួយផ្តល់ព័ត៌មានពាក់ព័ន្ធដល់ជន ឬក្រុមជនដែលផលិត ឬប្រើប្រាស់ឯកសារក្លែងបន្លំនេះ ដើម្បីធ្វើការឃោសនាបំភ័ន្តសាធារណៈមតិ ។

ទទួលបានសេចក្តីណែនាំនេះ គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ស្នងការដ្ឋាននគរបាល បញ្ជាការដ្ឋានកងរាជអាវុធហត្ថ រាជធានី ខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធត្រូវចាត់តាំងអនុវត្តឲ្យមានប្រសិទ្ធភាព និងចាត់ទុកជាការបន្ទាន់ ។

**គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍**
**ប្រធាន**

ស ខេង

**ចម្លងជូនៈ**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន គ.ជ.ប
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧០០ សហវ - ១៦.០៧.១៣

# ប្រកាស
# ស្តីពី
# ការបោះផ្សាយសញ្ញាបណ្ណរដ្ឋដើម្បីបំពេញដើមទុនបន្ថែម ជូនក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា-រី"

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១ ស្ដីពីការធានារ៉ាប់រង
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

បោះផ្សាយសញ្ញាបណ្ណរដ្ឋចំនួន ២៤០ (ពីររយសែសិប) ប័ណ្ណ ដើម្បីបំពេញដើមទុនបន្ថែមជូនក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា។

**ប្រការ ២.-**

សញ្ញាបណ្ណរដ្ឋ ត្រូវបានបោះផ្សាយនៅថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១៣ ដែលមានតម្លៃចារឹកក្នុងមួយឯកតា ១០,០០០,០០០៛(ដប់លាន) រៀល។

**ប្រការ ៣.-**

សញ្ញាបណ្ណរដ្ឋត្រូវបានបោះផ្សាយសម្រាប់រយៈពេល ០៣( បី) ឆ្នាំ តាមឥណប្រតិទានកំណត់ក្នុងសន្លឹកបណ្ណ។ ក្នុងរយៈពេលនេះ អ្នកកាន់សញ្ញាបណ្ណរដ្ឋត្រូវបានទទួលការប្រាក់ប្រចាំឆ្នាំចំនួន ៣% ហើយការទូទាត់ការប្រាក់នឹងត្រូវធ្វើឡើងជារៀងរាល់ ០៦(ប្រាំមួយ) ខែម្ដង ដោយឈរលើមូលដ្ឋាន ០៦ ខែ ស្មើ ១៨០ថ្ងៃ និងមួយឆ្នាំស្មើ ៣៦០ ថ្ងៃ។

**ប្រការ ៤.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិធ្វើសំណងសញ្ញាបណ្ណរដ្ឋមុនឥណប្រតិទាន ដែលបានកំណត់ក្នុងសន្លឹកបណ្ណ អាស្រ័យលើស្ថានភាពថវិការបស់រដ្ឋ។

**ប្រការ ៥.-**

នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ទទួលបន្ទុកតាមដានរាល់ស្ថានភាពបំណុលនៃសញ្ញាបណ្ណរដ្ឋ ព្រមទាំងសហការផ្ដល់ព័ត៌មានគ្នាទៅវិញទៅមកជាមួយនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ។

**ប្រការ ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

***កន្លែងទទួល:***

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ធនាគារជាតិនៃកម្ពុជា
- ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា (កម្ពុជា-រី)
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៧ សហវ

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៣

# សារាចរណែនាំ

## ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំ
## គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៤

យោងសារាចរណែនាំលេខ ០៩ សរណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

យោងអនុក្រឹត្យលេខ ៣៦ អនក្រ.ប.ក ចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក។

យោងអនុក្រឹត្យលេខ ១៧២ អនក្រ.ប.ក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក

យោងប្រកាសលេខ ២៨៥ សហវ.ប្រក.ហម ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកាឆ្នាំ២០១៤ របស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម ៖

គម្រោងចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបានរៀបចំទៅតាមទម្រង់និងចំណាត់ថ្នាក់នៃមាតិកាថវិកា ដូចបានចែងក្នុងតារាងឧបសម្ព័ន្ធទី១ ( តារាងសរុបចំណូលថវិការបស់ថ្នាក់រដ្ឋបាលនីមួយៗ ) តារាងឧបសម្ព័ន្ធទី២ (តារាងសរុបចំណាយថវិការបស់ថ្នាក់រដ្ឋបាលថ្នាក់នីមួយៗ)។

ថ្នាក់រដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដកស្រង់ខ្លឹមសារចំណាត់ថ្នាក់នៃមាតិកាថវិកាណាដែលមានការពាក់ព័ន្ធដើម្បីរៀបចំគម្រោងថវិការបស់ខ្លួន និងផ្ញើជូនទៅតាមការកំណត់ដូចខាងក្រោមៈ

រដ្ឋបាលសង្កាត់ត្រូវផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សាសង្កាត់បានអនុម័តរួចទៅរដ្ឋបាលក្រុងនិងរដ្ឋបាលរាជធានីយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៣។

រដ្ឋបាលខណ្ឌត្រូវផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សាខណ្ឌបានអនុម័តរួចទៅរដ្ឋបាលរាជធានីយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៣។

រដ្ឋបាលឃុំត្រូវផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សាឃុំបានអនុម័តរួចទៅរដ្ឋបាលខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

រដ្ឋបាលក្រុងត្រូវផ្ញើគម្រោងថវិកា (រួមបញ្ចូលទាំងគម្រោងថវិកាសង្កាត់) ដែលក្រុមប្រឹក្សាក្រុងបានអនុម័តទៅរដ្ឋបាលខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣។

រដ្ឋបាលខេត្តត្រូវផ្ញើគម្រោងថវិកាដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួចទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣។

រដ្ឋបាលរាជធានីត្រូវផ្ញើគម្រោងថវិកា(រួមបញ្ចូលគម្រោងថវិកាខណ្ឌនិងសង្កាត់)ដែលក្រុមប្រឹក្សារាជធានីបានអនុម័តរួចទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំកម្មវិធីដោយសម្របសម្រួលជាមួយអភិបាលនៃគណៈអភិបាលខេត្តដើម្បីពិនិត្យនិងបញ្ជាក់នីត្យានុកូលភាពលើគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកដោយមានការចូលរួមពីមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវធ្វើការបូកសរុបថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រចាំរាជធានី ខេត្តនីមួយៗតាមគំរូតារាងឧបសម្ព័ន្ធទី១«ក»,១«ខ» និង ១«គ»(តារាងសរុបចំណូលថវិការបស់រាជធានី ខេត្ត ក្រុង) និងគំរូតារាងឧបសម្ព័ន្ធទី២«ក»,២«ខ»និង ២«គ» (តារាងសរុបចំណាយថវិការបស់រាជធានី ខេត្ត ក្រុង) និងផ្ញើជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣។

ការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគោរពទៅតាមគោលការណ៍តុល្យភាពនៃថវិកា។ រាល់ការវិភាជន៍ខ្ទង់ចំណាយលម្អិតទាំងអស់ត្រូវស្ថិតក្នុងក្របខ័ណ្ឌដែលគម្រោងចំណូលសរុបអាចធានាប៉ាប់រងបានជាក់ស្តែង អាណាប័កនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវធ្វើការគិតគូររៀបចំគម្រោងចំណូលសរុបដើម្បីធ្វើជាមូលដ្ឋានក្នុងការវិភាជន៍គម្រោងចំណាយ។

## ក- អំពីគម្រោងចំណូល

ចំណូលក្នុងស្រុកថវិការដ្ឋឆ្នាំ២០១៤ ត្រូវសម្រេចឲ្យបាន១៥,២៣% នៃផ.ស.ស(ថ្នាក់ជាតិ១៤,២៤% និងថ្នាក់ក្រោមជាតិ០,៩៩%)។ ចំណូលចរន្តថវិការដ្ឋដែលត្រូវសម្រេចឲ្យបាន១៥,០៦% នៃផ.ស.ស គឺចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាត្រូវសម្រេចឲ្យបាន៦,៧០%នៃផ.ស.ស ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឲ្យបាន៥,៩០%នៃផ.ស.ស (ថ្នាក់ជាតិ៤,៩៦%និងថ្នាក់ក្រោមជាតិ០,៩៤%)។

## ក-១- គម្រោងចំណូលចរន្ត

**ក-១-១-** ថ្នាក់រដ្ឋបាលរាជធានី ខេត្ត ការរៀបចំគម្រោងចំណូលត្រូវបានរៀបចំលើមូលដ្ឋានប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធដែលបានកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទប្បញ្ញត្តិច្បាប់ទាំងឡាយជាធរមាន ។

-ចំណូលសារពើពន្ធ ត្រូវបានគិតគូរដោយផ្អែកលើ ៖

+ លទ្ធផលដែលសម្រេចបានក្នុងឆ្នាំកន្លងមក



82

+ លទ្ធផលដែលទទួលបាន និងការប៉ាន់ស្មានលទ្ធផលសរុបដែលអាចសម្រេចបានក្នុងឆ្នាំកំពុងអនុវត្ត
+ ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានគិតពន្ធ
+ ប៉ាន់ស្មានលើការវិវត្តសេដ្ឋកិច្ចនៅពេលខាងមុខ
+ ការប្រែប្រួលដែលអាចកើតមានឡើងដោយអត្រា និងចំនួនមូលដ្ឋានប្រមូលពន្ធ
+ ចំណូលដែលសង្ឃឹមថាបានមកពីការបង្កើតប្រភេទពន្ធថ្មី ។

- ចំណូលមិនមែនសារពើពន្ធ ត្រូវបានគិតគូរដោយផ្អែកលើ ៖
  + កិច្ចការទាំងឡាយដែលនាំឲ្យមានផលទុនចំណូលដូចជា កិច្ចសន្យាជួល សៀវភៅបន្ទុកសេវាកម្ម និងការកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
  + ស្ថិតិមុខសញ្ញាប្រមូលក្នុងឆ្នាំកំពុងអនុវត្តនិងការវិវត្តសេដ្ឋកិច្ចដែលនាំមកនូវមុខសញ្ញាចំណូលថ្មី
  + ស្ថិតិបំណុលដែលពុំទាន់បានដោះស្រាយ

**ក-១-១-១-** ដោយឡែកចំពោះគម្រោងចំណូលសរុបរបស់រដ្ឋបាលរាជធានី ត្រូវរួមបញ្ចូលទាំងគម្រោងចំណូលរបស់ខណ្ឌ និងសង្កាត់ទាំងអស់ចំណុះរដ្ឋបាលរាជធានីដែលបានពីការវិភាជន៍និងផ្ទេរមកពីមូលនិធិឃុំ សង្កាត់នៅថ្នាក់ជាតិ និងចំណូលដែលរដ្ឋបាលខណ្ឌ និងសង្កាត់ប្រមូលបានដោយខ្លួនឯង។

លើមូលដ្ឋានកញ្ចប់គម្រោងចំណូលថវិកាប្រចាំឆ្នាំដែលបានកំណត់រួច អភិបាលនៃគណៈអភិបាលរាជធានីត្រូវធ្វើការបែងចែក និងជូនដំណឹងអំពីកញ្ចប់ថវិការបស់ខណ្ឌ និងសង្កាត់នីមួយៗ ដើម្បីរៀបចំគម្រោងថវិកាលម្អិតរបស់ខ្លួន ។

**ក-១-១-២-** ការបែងចែកកញ្ចប់ថវិកាសម្រាប់ខណ្ឌនីមួយៗត្រូវផ្អែកលើ ៖

- កញ្ចប់ថវិការបស់ខណ្ឌនីមួយៗដែលបានប្រើប្រាស់ក្នុងឆ្នាំកន្លងមក
- តម្រូវការចាំបាច់មួយចំនួនរបស់ខណ្ឌនីមួយៗដែលបានកំណត់ជាធរមាន
- តម្រូវការក្នុងការអនុវត្តមុខងារដែលអភិបាលនៃគណៈអភិបាលរាជធានីពិនិត្យឃើញថាសមស្របត្រូវធ្វើប្រតិភូកម្មទៅឲ្យអភិបាលនៃគណៈអភិបាលខណ្ឌនីមួយៗ។

**ក-១-១-៣-** ការបែងចែកកញ្ចប់ថវិកាសម្រាប់សង្កាត់នីមួយៗត្រូវផ្អែកលើ ៖

- កញ្ចប់មូលនិធិសង្កាត់នីមួយៗដែលទទួលបានពីការវិភាជន៍មូលនិធិឃុំ សង្កាត់ពីថ្នាក់ជាតិ
- ចំណូលដែលរដ្ឋបាលសង្កាត់ប្រមូលបានដោយខ្លួនឯង
- តម្រូវការក្នុងការអនុវត្តមុខងារដែលអភិបាលនៃគណៈអភិបាលរាជធានីពិនិត្យឃើញថាសមស្របត្រូវធ្វើប្រតិភូកម្មទៅឲ្យចៅសង្កាត់នីមួយៗ។

**ក-១-២-** ថ្នាក់រដ្ឋបាលក្រុង ស្រុក ការរៀបចំគម្រោងចំណូលត្រូវផ្អែកលើតួលេខដែលបានវិភាជន៍និងផ្ទេរមកពីថ្នាក់ជាតិនូវមូលនិធិក្រុង ស្រុក ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានជូនដំណឹង និងចំណូលដែលរដ្ឋបាល

ក្រុង ស្រុករកបានដោយខ្លួនឯង។ នៅឆ្នាំខាងមុខ រដ្ឋបាលក្រុង ស្រុកនឹងទទួលបាននូវប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធដែលកំណត់ដោយលិខិតបទដ្ឋាន និងបទប្បញ្ញត្តិច្បាប់ដោយឡែក។

ដោយឡែកចំពោះគម្រោងចំណូលសរុបរបស់ក្រុង ត្រូវរួមបញ្ចូលទាំងចំណូលរបស់សង្កាត់ទាំងអស់ ចំណុះរដ្ឋបាលក្រុងដែលបានវិភាជន៍និងផ្ទេរមកពីមូលនិធិឃុំ សង្កាត់នៅថ្នាក់ជាតិ និងចំណូលដែលរដ្ឋបាលសង្កាត់ប្រមូលបានដោយខ្លួនឯង។

លើមូលដ្ឋានកញ្ចប់គម្រោងចំណូលថវិកាប្រចាំឆ្នាំដែលបានកំណត់រួច អភិបាលនៃគណៈអភិបាលក្រុងត្រូវធ្វើការបែងចែកនិងជូនដំណឹងអំពីកញ្ចប់ថវិការបស់សង្កាត់នីមួយៗដើម្បីរៀបចំគម្រោងថវិកាលម្អិតរបស់ខ្លួន។

**ក-១-៣-** ថ្នាក់រដ្ឋបាលខណ្ឌ និងសង្កាត់ចំណុះរាជធានី ការរៀបចំគម្រោងចំណូលត្រូវផ្អែកលើកញ្ចប់ថវិកាដែលបានបែងចែកនិងជូនដំណឹងពីរដ្ឋបាលរាជធានី។

**ក-១-៤-** ថ្នាក់រដ្ឋបាលសង្កាត់ចំណុះក្រុង ការរៀបចំគម្រោងចំណូលត្រូវផ្អែកលើកញ្ចប់ថវិកាដែលបានបែងចែកនិងជូនដំណឹងពីរដ្ឋបាលក្រុង។

**ក-១-៥-** ថ្នាក់រដ្ឋបាលឃុំ ការរៀបចំគម្រោងចំណូលត្រូវផ្អែកលើតួលេខដែលបានវិភាជន៍ និងផ្ទេរពីថ្នាក់ជាតិនូវមូលនិធិឃុំ សង្កាត់ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានជូនដំណឹងតាមរយៈរដ្ឋបាលខេត្តនិងចំណូលរដ្ឋបាលផ្សេងៗដែលប្រមូលបាននៅមូលដ្ឋានរបស់ឃុំ។

## ក-២- គម្រោងចំណូលមូលធន

ចំណូលជាមូលធននៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចបានមកពីការផ្ទេរឥណទានពីថវិកាថ្នាក់ជាតិ និងចំណូលមូលធនដែលមានប្រភពនៅនឹងមូលដ្ឋានផ្ទាល់។ ដូចនេះពេលរៀបចំគម្រោងចំណូលជាមូលធនគ្រប់ថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលឲ្យអស់នូវជំនួយមនុស្សធម៌និងជំនួយពីបរទេសដែលសប្បុរសជន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានាបានសន្យាផ្តល់ហិរញ្ញប្បទានផ្ទាល់ដល់ថវិការបស់រដ្ឋបាលនីមួយៗរួចហើយ។

## ខ- អំពីគម្រោងចំណាយ

ចំណាយសរុបថវិការដ្ឋឆ្នាំ២០១៤ ត្រូវរក្សាឲ្យនៅត្រឹម២០,១៣% នៃផ.ស.ស (ថ្នាក់ជាតិ១៩,៣៣% និងថ្នាក់ក្រោមជាតិ០,៩៩%) ដោយចំណាយចរន្តថវិការដ្ឋនឹងកម្រិតត្រឹម១២,០៦%នៃផ.ស.ស(ថ្នាក់ជាតិ ១១,៤៧% និងថ្នាក់ក្រោមជាតិ០,៧៨%) ក្នុងនោះរាជរដ្ឋាភិបាលកំពុងរៀបចំកែលម្អប្រព័ន្ធបៀវត្ស និងរៀបចំគោលនយោបាយដំឡើងប្រាក់បៀវត្សដោយផ្អែកលើកំណើនសេដ្ឋកិច្ច អតិផរណា និងលទ្ធភាពថវិកា ក្នុងទិសដៅលើកកម្ពស់ផលិតភាពការងារ បង្កើនប្រសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ និងធានាបាននូវសមធម៌ ព្រមទាំងរក្សាបាននូវស្ថេរភាព និងចីរភាពហិរញ្ញវត្ថុសាធារណៈ និងម៉ាក្រូសេដ្ឋកិច្ច។ ថវិការាជធានី ខេត្ត ត្រូវកំណត់ត្រឹម

០,៩៩% នៃ ផ.ស.ស ដែលក្នុងនោះថវិកាផ្ទាល់របស់រាជធានី ខេត្តសរុបមានប្រមាណ០,៧៩% នៃផ.ស.ស មានកំណើន០,០៩% នៃផ.ស.ស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រាជធានី ខេត្ត និងក្រុង ស្រុក ស្មើនឹង០,២០% នៃផ.ស.ស ដែលក្នុងនោះថវិកាដែលត្រូវផ្ទេរសម្រាប់មូលនិធិក្រុង ស្រុកសម្រាប់ឆ្នាំ២០១៤ ត្រូវបានកំណត់ស្មើនឹង ០,៨% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៣។

ថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវដំណើរការរៀបចំគម្រោងចំណាយថវិកាដោយផ្អែកលើគោលការណ៍ដូចខាងក្រោម ៖

- ត្រូវស្ថិតក្នុងក្របខ័ណ្ឌដែលលទ្ធភាពសរុបចំណូលអាចធានារ៉ាប់រងបាន
- ត្រូវបានរៀបចំដោយវិចារណកម្មទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធ
- ត្រូវលម្អិតទៅតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធនិងទៅតាមលំដាប់លំដោយនៃអាទិភាពចំណាយ។

## ខ-១- គម្រោងចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត

ក្របខណ្ឌថវិកាបានគ្រោងចំណូល-ចំណាយថ្នាក់ក្រោមជាតិជារួម ឲ្យមានតុល្យភាព ដោយពុំមានការចាំបាច់ក្នុងការឧបត្ថម្ភពីថ្នាក់ជាតិ ដល់រាជធានី ខេត្តទេ។ ទោះជាយ៉ាងណាក្តី យើងនៅមានបញ្ហាប្រឈមមួយគឺការផ្ទេរធនធានពីខេត្តមានអតិរេក ទៅខេត្តឱនភាព គឺជាការលំបាក។ ដើម្បីដោះស្រាយបញ្ហានេះ ថវិការាជធានីខេត្តនីមួយៗ មិនអាចមានកំណើនស្មើគ្នាបានឡើយ ដោយខេត្តមានចំណូលខ្ពស់ដូចជារាជធានីភ្នំពេញ ឬខេត្តសៀមរាប គួរត្រូវបានអនុញ្ញាតឲ្យបង្កើនចំណាយលើសពីកំណើនមធ្យមភាគ ២១,២%។ ដោយឡែក ខេត្តមានចំណូលទាបអនុញ្ញាតឲ្យមានកំណើនទាបជាង ព្រោះត្រូវបានឧបត្ថម្ភថវិកាពីថ្នាក់ជាតិ។

**ខ-១-១-** គម្រោងចំណាយរបស់រដ្ឋបាលរាជធានីត្រូវបានរៀបចំលម្អិតតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានសរុបចំណូលក្រោយពីបានដកចេញនូវកញ្ចប់ថវិកាខណ្ឌនិងកញ្ចប់ថវិកាសង្កាត់ចំណុះរាជធានីរួចហើយ នឹងត្រូវបានបូកបញ្ចូលជាមួយគម្រោងចំណាយរបស់រដ្ឋបាលខណ្ឌនិងសង្កាត់ក្រោយពេលដែលរដ្ឋបាលខណ្ឌ និងសង្កាត់បានផ្ញើជូននូវគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

**ខ-១-២-** គម្រោងចំណាយរបស់រដ្ឋបាលខេត្ត ត្រូវបានរៀបចំលម្អិតតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលមានការពាក់ព័ន្ធដោយផ្អែកលើគម្រោងចំណូលសរុបដែលបានគណនារួច។

## ខ-២- គម្រោងចំណាយរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ

**ខ-២-១-** គម្រោងចំណាយរបស់រដ្ឋបាល ក្រុង ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនី ស្រប

តាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានសរុបចំណូល ក្រោយពីបានដកចេញនូវកញ្ចប់ថវិកាសង្កាត់ចំណុះក្រុងរួចហើយ នឹងត្រូវធ្វើការបូកបញ្ចូលជាមួយគម្រោងចំណាយរបស់រដ្ឋបាលសង្កាត់ក្រោយពេលដែលសង្កាត់ចំណុះក្រុង បានផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

**ខ-២-២-** គម្រោងចំណាយរបស់រដ្ឋបាល ស្រុក ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និង អនុគណនី ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានសរុបចំណូលដែលបានគណនារួច។

**ខ-២-៣-** គម្រោងចំណាយរបស់រដ្ឋបាល ខណ្ឌ ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនី ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធ ដោយផ្អែកលើមូលដ្ឋានកញ្ចប់ថវិកាដែលរដ្ឋបាលរាជធានីបានជូនដំណឹង។

## ខ-៣- គម្រោងចំណាយរបស់រដ្ឋបាលឃុំ សង្កាត់

**ខ-៣-១-** គម្រោងចំណាយរបស់រដ្ឋបាល ឃុំ ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដោយផ្អែកលើមូលដ្ឋានសរុបចំណូលដែលបានគណនារួច។

**ខ-៣-២-** គម្រោងចំណាយរបស់រដ្ឋបាល សង្កាត់ ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនី ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានកញ្ចប់ថវិកាដែលរដ្ឋបាលរាជធានី និងរដ្ឋបាលក្រុងបានជូនដំណឹង។

## គ- ការរៀបចំគម្រោងចំណាយ

ចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយតាមជំពូក គណនី អនុគណនី ដើម្បីបង្ហាញឲ្យឃើញថាការគិតគូរចំណាយរបស់ខ្លួនមានភាពត្រឹមត្រូវហ្មត់ចត់ និងសមហេតុផល ហើយលិខិតយុត្តិការទាំងអស់នេះ ទុកសម្រាប់ធ្វើជាមូលដ្ឋានលើការពិនិត្យនីត្យានុកូលភាពនៃថវិកា។

## គ-១- ការរៀបចំគម្រោងចំណាយចរន្ត

### គ-១-១- ប្រភេទ ១ ៖ មធ្យោបាយសេវា

